# 소망의 여인들

## Prayer Calander

2024년 5월

**ប្រតិទិនអធិស្ឋានចេញផ្សាយជារៀងរាល់ខែ ដែលមានជាង 100ភាសា និងមានអ្នកចូលរួមអធិស្ឋានជាង 110,000នាក់**



**ការអធិស្ឋានសម្រាប់ស្ត្រីអាស៊ី 1**

អាស៊ីគឺជាទ្វីបដែលធំ និងមានប្រជាជនច្រើនជាងគេលើពិភពលោក ដែលមានប្រជាជនចំនួន 60% រស់នៅ។ ស្ត្រីរាប់លាននាក់នៅអាស៊ីខ្វះលទ្ធភាពទទួលបានការអប់រំ ដោយសារតែភាពក្រីក្រ ការមាក់ងាយក្នុងសង្គម និងការរើសអើង។ នៅអាស៊ីខាងត្បូង កុមារីជាច្រើនប្រឈមមុខនឹងការបៀតបៀន វាយដំ ចាប់ពង្រត់ ឬសម្លាប់ពេលធ្វើដំណើរទៅសាលារៀន។ ដែលធ្វើអោយស្ត្រីជាច្រើនឈប់រៀននៅពេលពួកគេពេញវ័យ។ ក្រុមការងាររបស់ស្ត្រីក្នុងក្តីសង្ឃឹមនៅអាស៊ីខាងត្បូងបានជួយពួកគេតាមរយៈកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈដែលផ្តល់ឱ្យពួកគេនូវជំនាញកាត់ដេរ សិប្បកម្ម និងកសិកម្ម ដែលអាចឱ្យពួកគេបង្កើតប្រាក់ចំណូល និងលើកកម្ពស់ជីវភាពរស់នៅរបស់ពួកគេផងដែរ។

카카오톡 채널에서 '소망의 여인들' 채널을 추가하시면 매주 월요일에 한국어 기도카드를 받으실 수 있습니다.

1. បិតាអើយ
សូមប្រទាននូវស្វាមីដែលជាគ្រិស្តបរិស័ទដល់ស្ត្រីជនជាតិចិនដែលមានជំនឿ ដើម្បីកុំឱ្យពួកគេមានសម្ពាធពីឪពុកម្តាយ ហើយជ្រើសរើសដៃគូដែលមិនជឿនោះឡើយ សូមប្រទាននូវភាពក្លាហានដល់ស្ត្រីទាំងនេះឱ្យនិយាយថាទេចំពោះការរួមរស់មុនអាពាហ៍ពិពាហ៍។ (ហេព្រើរ ១៣:៤)

2. ព្រះអម្ចាស់អើយ សូមការពារស្ត្រីនៅក្នុងប្រទេសអាហ្វហ្គានីស្ថាន ដែលប្រឈមមុខនឹងការបៀតបៀន និងអំពើហឹង្សានៅក្នុងគ្រួសាររបស់ពួកគេ។ (អេសាយ ៤១:១០)

3. ព្រះដ៏ជាអម្ចាស់ សូមឲ្យស្ត្រីនៅក្នុងប្រទេសមីយ៉ាន់ម៉ា ទទួលបានសេវាសុខភាពកាន់តែច្រើនឡើង ដើម្បីអោយសុខភាពមាតាមានការប្រសើរឡើង និងកាត់បន្ថយការស្លាប់របស់ទារក។ (យេរេមា ១៧:១៤)

4. ឱព្រះវរបិតាអើយ
សូមនាំមនុស្សជាច្រើនអោយចូលរួមនៅក្នុងព្រះវិហារនៅប្រទេសជប៉ុន ហើយអនុញ្ញាតឱ្យពួកគេរក្សាការរួបរួមនៃព្រះវិញ្ញាណ និយាយការពិតដោយសេចក្តីស្រឡាញ់ និងមានភាពចាស់ទុំដូចជាព្រះគ្រីស្ទ។ (អេភេសូរ ៤:១-១៦)

5. ព្រះអង្គអើយ
យើងអធិស្ឋានសុំអោយមានទឹកស្អាតនៅតាមជនបទនៃប្រទេសឥណ្ឌា។ សូមផ្តល់សុខភាព និងកម្លាំងដល់ស្ត្រី ក្នុងការដែលពួកគេព្យាយាមសន្សំទឹកសម្រាប់គ្រួសារ និងសត្វចិញ្ចឹមរបស់ពួកគេប្រើប្រាស់។ ( ៣យ៉ូហាន ១:២ )

6. ព្រះអម្ចាស់អើយ
សូមជួយស្វាមីភរិយានៅប្រទេសសិង្ហបុរីឱ្យមានលទ្ធភាពក្នុងការមានកូន និងចែករំលែកការទទួលខុសត្រូវទៅលើការថែទាំកូនផងដែរ។ (លោកុប្បត្តិ ១:២៨)

7. ព្រះអម្ចាស់អើយ
ទូលបង្គំអធិស្ឋានសូមឱ្យយុវជននៅប្រទេសកូរ៉េខាងត្បូងធ្វើតាមគោលការណ៍ក្នុងទំនាក់ទំនងដែលទ្រង់បានមានបន្ទូលអំពីការទាក់ទងគ្នាតាមរយៈព្រះគម្ពីរ ហើយធ្វើការរៀបការជាជាងរស់នៅជាមួយគ្នាដោយមិនបានរៀបការ។ (ម៉ាថាយ ១៩:៤-៦)

8. ព្រះអម្ចាស់អើយ
សូមនាំមកនូវការផ្លាស់ប្តូរវប្បធម៌ដែលនឹងបញ្ឈប់ការអនុវត្តអាពាហ៍ពិពាហ៍ ដែលបង្កគ្រោះថ្នាក់ដល់ស្ត្រីនៅក្នុងប្រទេសប៉ាគីស្ថាន។ សូមបញ្ចប់ការសម្លាប់ ការបង់ថ្លៃកូនក្រមុំ និងការលក់កូនស្រីឲ្យក្លាយជាអ្នកបម្រើនេះអោយបាត់ទៅក្នុងប្រវត្តិសាស្ត្រប្រទេសប៉ាគីស្ថានផងដែរ។ (ទំនុកតម្កើង ៧:១-២)

9. បិតាអើយ សូមដឹកនាំក្រុមការងារនៅអាស៊ីអាគ្នេយ៍របស់យើង នៅពេលដែលពួកគេមានគម្រោងបង្កើតកម្មវិធីស្ត្រីក្នុងក្តីសង្ឃឹម និងនាំមកនូវដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទជាភាសាម៉ាឡេនៅឆ្នាំនេះផងដែរ។ (ទំនុកតម្កើង ៩៦:៣)

10. សូមពង្រឹងចំណងអាពាហ៍ពិពាហ៍នៅម៉ុងហ្គោលី ព្រះអម្ចាស់អើយ។ សូមការពារ ប្រទានពរ និងសម្រាលទុក្ខម្តាយដែលនៅលីវដែលទទួលបន្ទុកធ្ងន់ក្នុងជីវិតគ្រួសារដោយសារការលែងលះ។ (ទំនុកតម្កើង ៦៨:៥)

11. ព្រះអង្គអើយ
សូមអោយស្ត្រីនៅប្រទេសនេប៉ាល់មានឱកាសទទួលបានការសិក្សាបន្ថែមទៀត ដើម្បីអោយពួកគេអាចអភិវឌ្ឍជំនាញដែលចាំបាច់សម្រាប់ការលូតលាស់ផ្ទាល់ខ្លួន និងការងារផងដែរ។ (សុភាសិត ១៦:១៦)

**TWR Korea 북방선교방송**
서울특별시 관악구 양녕로 15, 월드빌딩 6층
전화 (02)886-5671 / 이메일 hskim@twrk.or.kr

12. ព្រះវរបិតាអើយ សូមប្រទានកម្លាំង និងការពារស្ត្រីនៅក្នុងប្រទេសកម្ពុជា នៅពេលពួកគេប្រឈមមុខនឹងការបៀតបៀនខាងព្រលឹងវិញ្ញាណ។ សូមឲ្យពួកគេឈរមាំមួនក្នុងសេចក្ដីជំនឿរបស់ពួកគេ ហើយរីកចម្រើនក្នុងការគោរពតាមព្រះបន្ទូលរបស់ទ្រង់ផងដែរ។ (ទំនុកតម្កើង ២៨:៧)

15. កូនសូមសរសើរព្រះនាមទ្រង់ ចំពោះឱកាសក្នុងការផលិតកម្មវិធីស្ត្រីក្នុងក្តីសង្ឃឹមជាភាសា Hmong ដើម្បីអោយជនជាតិ Hmong ដែលរស់នៅក្នុងប្រទេសឡាវភាគខាងជើង វៀតណាម និងប្រទេសថៃបានស្តាប់ផងដែរ។ (២សាំយ៉ូអែល ២២:៥០)

16. ព្រះអម្ចាស់អើយ សូមអោយក្មេងជំនាន់ក្រោយរបស់ប្រទេសចិន បាននៅជាប់ជាមួយទ្រង់ និងទទួលបានការការពារ ការព្យាបាល និងការដឹកនាំពីទ្រង់ផងដែរ។ សូមឱ្យពួកគេនាំយកទំនាក់ទំនង ការងារ និងតម្រូវការផ្សេងទៀតមានទូលថ្វាយដល់ទ្រង់។ (ម៉ាថាយ ៧:៧)

17. បិតាអើយ សូមឲ្យក្រុមជនជាតិភាគតិចនៅក្នុងប្រទេសអាហ្វហ្គានីស្ថាន ទទួលបានដំណឹងល្អ ហើយដឹងថាពួកគេមានតម្លៃ ដោយសារពួកគេត្រូវបានបង្កើតឡើងអោយដូចជារូបអង្គទ្រង់។ (លោកុប្បត្តិ ១:២៧)

18. ព្រះអម្ចាស់អើយ សូមអនុញ្ញាតឱ្យរដ្ឋាភិបាលនៃប្រទេសមីយ៉ាន់ម៉ា បានការពារស្ត្រីនៅទីនោះ ដើម្បីអោយពួកគេអាចធ្វើការ និងរស់នៅដោយសុវត្ថិភាព ក្នុងពេលដែលមានការកើនឡើងនៃអំពើហិង្សា និងភាពអសន្តិសុខនៅទីនោះ។ (ទំនុកតម្កើង ២៣:៤)

19. ព្រះអម្ចាស់អើយ សូមអោយស្ត្រីជាច្រើននៅក្នុងប្រទេសជប៉ុនបានសង្គ្រោះ តាមរយៈការចាក់ផ្សាយរបស់ស្ត្រីក្នុងក្តីសង្ឃឹម។ សូមប្រទានអោយមានកំណើនកើនឡើងនៃអ្នកគាំទ្រ និងផ្គត់ផ្គង់ប្រចាំខែបន្ថែមទៀតដល់ព័ន្ធកិច្ចនេះផងដែរ។ (អេសាយ ៥២:៧-១០)

20. បិតាអើយ សូមការពារស្ត្រីនៅក្នុងប្រទេសឥណ្ឌាពីការចាប់ពង្រត់ ការរំលោភបំពាន ការរំលោភ និងអំពើឃោរឃៅផ្សេងទៀតដែលប្រព្រឹត្តដោយស្វាមី និងសាច់ញាតិរបស់ស្វាមីរបស់ពួកគេ។ (កូឡុស ៣:១៩)

21.សូមទ្រង់ប្រទានព្រះពរដល់ការខិតខំប្រឹងប្រែងក្នុងការប្រមូលថវិកាដើម្បីចាប់ផ្តើមថ្នាក់ព្រះគម្ពីរនៅភាគខាងជើងប្រទេសវៀតណាមសម្រាប់ស្ត្រីដែលបានបញ្ចប់ថ្នាក់អនុវិទ្យាល័យ និងសម្រាប់ភរិយារបស់គ្រូគង្វាល។ (រ៉ូម ១២:២)

22. ព្រះវរបិតាអើយ ទូលបង្គំអធិស្ឋានសម្រាប់អស់អ្នកដែលបានភៀសខ្លួនពីប្រទេសកូរ៉េខាងជើង ទៅកាន់ប្រទេសកូរ៉េខាងត្បូង។ សូមផ្តល់សេចក្តីមេត្តាករុណាដល់ពួកគេ នៅពេលពួកគេតាំងទីលំនៅកន្លែងថ្មី។ (លេវីវិន័យ ១៩:៣៣-៣៤)

23. ព្រះអម្ចាស់អើយ យើងអធិស្ឋានសូមឱ្យប្រព័ន្ធវេជ្ជសាស្ត្រនៅក្នុងប្រទេសប៉ាគីស្ថានបានផ្លាស់ប្តូរ ដើម្បីអោយស្ត្រីទីនោះទទួលបានការព្យាបាល។ សូមឲ្យការថែទាំសុខភាពត្រូវបានកែលម្អនៅទីនោះ ជាពិសេសចំពោះបញ្ហាសុខភាពស្ត្រី បិតាអើយ។ (ទំនុកតម្កើង ១៣៩:១៣-១៥)

24. ព្រះជាម្ចាស់អើយ ទ្រង់បានប្រោសដួងចិត្ត និងគំនិតស្ត្រីក្នុងប្រទេសកម្ពុជា ដែលធ្លាប់មានរបួស និងទុក្ខលំបាក។ សូមនាំពួកគេឱ្យមានសន្តិភាព ការលួងលោម និងស្តារផ្លូវចិត្តរបស់ពួកគេឡើងវិញផងដែរ។ (ទំនុកតម្កើង ១៤៧:៣)

25. ព្រះអម្ចាស់អើយ សូមណែនាំអ្នកដឹកនាំឱ្យកែលម្អប្រព័ន្ធថែទាំសុខភាពនៅប៉ាពួញូហ្គីណេ ដែលមានការខ្វះថវិកាតែអត្រានៃជំងឺគ្រុនចាញ់ និងជំងឺទឹកនោមផ្អែមបានកើនឡើងដែលលើសលប់។ (យេរេមា ៣៣:៦)

26.មានក្មេងស្រីជនជាតិម៉ុងហ្គោលីវ័យក្មេងជាច្រើននាក់កំពុងសម្រាលកូន មិនគ្រប់ខែ និង ឆ្លងជំងឺកាមរោគ។ ព្រះអម្ចាស់អើយ សូមជួយពួកគេឱ្យមើលឃើញពីប្រាជ្ញារបស់ទ្រង់ ហើយរក្សាភាពបរិសុទ្ធរហូតដល់ពួកគេទទួលបានអាពាហ៍ពិពាហ៍។ (យ៉ាកុប ១:១៥)

27. បិតាអើយ សូមផ្តល់ឱកាសដល់ស្ត្រីនៅក្នុងប្រទេសនេប៉ាល់ ក្នុងការពង្រឹងទំនាក់ទំនងរបស់ពួកគេជាមួយទ្រង់ និងរកឃើញការកំសាន្តចិត្តនៅដំណើរនៃសេចក្ដីជំនឿរបស់ពួកគេផងដែរ។ (យ៉ាកុប ៤:៨)

28. ព្រះជាអម្ចាស់អើយ សូមអនុញ្ញាតឱ្យក្រុមការងារនៅតណ្ឌនេស៊ីរបស់យើង អោយពួកគេប្រមូលមូលនិធិគ្រប់គ្រាន់នៅក្នុងប្រទេស ដើម្បីអោយពួកគេអាចបង្កើតព័ន្ធកិច្ចសួរសុខទុក ដើក្នុងការផ្តល់ការណែនាំខាងព្រលឹងវិញ្ញាណដល់អ្នកស្តាប់កម្មវិធី និងឆ្លើយតបទៅនឹងតម្រូវការរបស់ពួកគេផងដែរ។ (យ៉ាកុប ១:២៧)

29. បិតាអើយ សូមឲ្យគ្រួសារនៅប្រទេសហ្វីលីពីនសម្លឹងទៅទ្រង់ជាអ្នកដែលផ្គត់ផ្គង់ និងដឹកនាំពួកគេ នៅពេលដែលពួកគេប្រឈមមុខនឹងការលំបាកជាច្រើនដូចជា បញ្ហាសុខភាព ហិរញ្ញវត្ថុ ទំនាក់ទំនង និងការងាររបស់គេផងដែរ។ (សុភាសិត ៣:៦)

30. ឱព្រះវរបិតាអើយ កូនសូមអធិស្ឋានសុំឱ្យមានការកែលម្អការថែទាំសុខភាពនៅក្នុងប្រទេសនេប៉ាល់ ដើម្បីឱ្យស្ត្រីនៅទីនោះមានធនធានសម្រាប់ដោះស្រាយតម្រូវការសុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់ពួកគេ។ (យេរេមា ៣០:១៧)

31.ក្នុងការដែលអ្នកស្តាប់កម្មវិធីស្ត្រីក្នុងក្តីសង្ឃឹមនៅប្រទេសវៀតណាម បានទៅលេងព្រះវិហា និងអ្នកដឹកនាំ សូមឲ្យពួកគេមានភាពចាស់ទុំក្នុងទំនាក់ទំនងរបស់ពួកគេជាមួយនឹងព្រះគ្រីស្ទ (រ៉ូម ១:១០)

**후원안내**

**국민은행 851-01-0003-724 북방선교방송**

**최초 입금 후 사무실로 연락주시기 바랍니다.**